*ការិយាល័យសារពត៌មាន*
**ក្រសួងសន្តិសុខមាតុភូមិសហរដ្ឋអាមេរិក**
500 C Street, SW
Washington, DC 20472

FEMA

ចុះកាលបរិច្ឆេទ:២០ កក្កដា ២០០៧
ការិយាល័យពត៌មាន FEMA
២០២-៦៤៦-៤៦០០

# សំនួរនិងចំលើយ

## សារធាតុហ្វ័រម៉ាល់ដេហាយដ៏ និងអ្នករស់នៅតាមរថសណ្តោង

ចុះកាលបរិច្ឆេទ: ២០ កក្កដា ២០០៧
លេខចេញផ្សាយ: FNF-07-028

### ១. តើ FEMA កំពុងធ្វើអ្វីខ្លះទាក់ទងនឹងសំនួរនិងភាពកង្វល់ផ្សេងៗអំពីឥទ្ធិពលសារធាតុហ្វ័រម៉ាល់ដេហាយដ៏ ចំពោះអ្នករស់នៅតាមរថសណ្តោងក្នុងតំបន់ឈូងសមុទ្រ?

សុខភាពនិងសុវត្ថិភាពរបស់ប្រជាជនមូលដ្ឋានគឺជាក្តីបារម្ភណ៍ចំបងរបស់ FEMA។ ទីភ្នាក់ងារយើងបានស្នើសុំជំនួយ និងជំនាញការពីមជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការរោគ(CDC) ដើម្បីវាយតំលៃសុខភាពសាធារណ:ទាក់ទងនឹងគុណភាពខ្យល់ក្នុងលំនៅដ្ឋានរបស់ជនរងគ្រោះដែលរស់នៅតាមរថសណ្តោងក្នុងតំបន់ឈូងសមុទ្រ។

### ២. ខ្ញុំស្មានថា FEMA បានធ្វើការសិក្សាលើអ្នករស់នៅតាមរថសណ្តោងរួចហើយ ។

ពិតណាស់។ រដូវក្តៅកន្លងទៅ ភ្នាក់ងារការពារបរិស្ថាន ភ្នាក់ងារគ្រប់គ្រងសារធាតុពុល និងភ្នាក់ងារគ្រប់គ្រងរោគរបស់ CDC បានធ្វើតេស្តពិសោធន៏ខ្យល់ពីលំនៅដ្ឋានរថសណ្តោង។ លទ្ធផលពិសោធន៏បានបង្ហាញថាការបំពាក់ប្រព័ន្ធបក់ខ្យល់តាមលំនៅដ្ឋាននិមួយៗមានប្រសិទ្ធភាពក្នុងការកាត់បន្ថយសារធាតុ ហ្វ័រម៉ាល់ដេហាយដ៏។ ទោះបីយ៉ាងណាក៏ដោយ FEMA នឹងបន្តធ្វើការសិក្សាស្រាវជ្រាវដើម្បីឆ្លើយតបទៅនឹងក្តីបារម្ភណ៍អំពីការប៉ះពាល់ដល់សុខភាពអ្នករស់នៅតាមរថសណ្តោងក្នុងរយ:យូរមួយ។

### ៣. តើការសិក្សាស្រាវជ្រាវថ្មីនឹងធ្វើឡើងយ៉ាងដូចម្តេច?

យើងនឹងធ្វើតេស្តលើគុណភាពខ្យល់ម៉ាស៊ីនត្រជាក់បំពាក់ក្នុងរថសណ្តោងដែលគេប្រើក្នុងជីវភាពជាក់ស្តែងប្រចាំថ្ងៃ។ ការសិក្សាដែលបានធ្វើឡើងកន្លងទៅមិញអនុវត្តន៏ចំពោះរថសណ្តោងថ្មីដែលយើងអាចវាស់វែងកំរិតហ្វ័រម៉ាល់ដេហាយដ៏នៅតាមរថសណ្តោងនិមួយៗបាន ព្រោះវាមិនទាន់មានភាពប្រែប្រួលបណ្តាលមកពីទង្វើរផ្សេងៗរបស់ អ្នករស់នៅតាមរថសណ្តោង ដូចជាការជក់បារីជាដើម។

សំនួរដ៏សំខាន់ដែល FEMA សុំ CDC អោយសិក្សាសង្កត់ធ្ងន់គឺ ទំនាក់ទំនងរវាងខ្យល់កខ្វក់ក្នុងរថសណ្តោង និង បញ្ហាផលប៉ះពាល់ដល់សុខភាពកុមារដែលរស់នៅតាមរថសណ្តោងនោះ។ ការសិក្សានេះនឹងតំរង់ទិសស្វែងរកនូវចំលើយរយ:ពេលខ្លី និងធ្វើការវាយតំលៃលើបរិស្ថានខាងក្នុងរថសណ្តោងសំរាប់រយ:ពេលវែង។

## ៤. តើ FEMA ចាត់ទុកហ្វ៊ រម៉ាល់ឌីអ៊ីតជាភាពគំរាមកំហែងដល់សុខភាពសាធារណៈជាលក្ខណៈធ្ងន់ធ្ងរកំរិតណា?

FEMA មិនមែនជាភ្នាក់ងារសុខភាព ហេតុនេះយើងបានប្រឹក្សាជាមួយភ្នាក់ងារនិងការិយាល័យសហព័ន្ធផ្សេងៗដែលមានយុត្តាធិការផ្នែកវេជ្ជសាស្រ្ត និងបច្ចេកទេសវិទ្យាសាស្រ្តដើម្បីធ្វើតេស្តនិងវាយតំលៃយ៉ាងត្រឹមត្រូវ យើងនឹងធ្វើការប្រមូលសរុបពត៌មានដ៏ត្រឹមត្រូវមួយស្តីពីផលប៉ះពាល់របស់ហ្វ៊រម៉ាល់ដេហាយដ៏លើប្រជាពលរដ្ឋដែលរស់នៅតាមរថសណ្តោងផ្គត់ផ្គង់ដោយ FEMA។ ទីភ្នាក់ងារទាំងនោះរួមមាន DHS OHA, EPA, CDC និងទីភ្នាក់ងាររង ព្រមទាំងការិយាល័យសុខាភិបាលប្រចាំរដ្ឋផ្សេងៗជាច្រើនទៀត។ FEMA មិនមែនជាអ្នកកំណត់នូវមាត្រដ្ឋាន(ស្តង់ដារ) សុខាភិបាល ហើយយើងក៏មិនមានជំនាញការផ្នែកសុខភាព រឺក៏សមត្ថភាពត្រួតពិនិត្យបញ្ហាសុខភាពនោះដែរ។ ដូច្នេះយើងនឹងស្តាប់តាមរាល់អនុសាសន៍ដែលផ្តល់អោយដោយទីភ្នាក់ងារដែលមានសិទ្ធិ និងភារកិច្ចទទួលខុសត្រូវក្នុងការពិនិត្យវាយតំលៃលើផលប៉ះពាល់ផ្សេងៗដែលបណ្តាលមកពីហ្វ៊រម៉ាល់ដេហាយដ៏ តាមលក្ខ័ណ្ឌជាក់លាក់ផ្សេងៗ ។

## ៥. តើហ្វ៊រម៉ាល់ដេហាយដ៏មានសារធាតុរួមផ្សំអ្វីខ្លះ?

គេរកឃើញមានហ្វ៊រម៉ាល់ដេហាយដ៏នៅនឹងសាច់ក្រណាត់សង្កត់អចិន្ត្រៃថ្មី កំរាលព្រំផ្សេងៗ ថ្នាំលាបផ្ទះ ថ្នាំក្រចកថ្នាំពេទ្យ គ្រឿងក្រអូប សាប៊ូលាងចាន សាប៊ូបន្ទន់សាច់ក្រណាត់ សារធាតុការពារទ្រនាប់ជើង សារធាតុសំអាតកំរាលព្រំ ការ សារធាតុស្អិតផ្សេងៗ ខ្មុកម្រ័ក្សណ៍ និងសារធាតុប្លាស្ទិច។ ផងដែ ហ្វ៊រម៉ាល់ដេហាយដ៏មាននៅនឹងបារី សារធាតុថ្នាំជក់ និងឧស្ម័នសំរាប់ចំអិនអាហារផ្សេងៗ។

## ៦. មកដល់ថ្ងៃនេះ តើ FEMA បានទទួលពាក្យបណ្តឹងប៉ុន្មានទាក់ទងនឹងសការក្តានុពលនៃការសាយភាយរបស់ហ្វ៊រម៉ាល់ដេហាយដ៏នៅតាមរថសណ្តោង?

ក្នុងចំណោមរថសណ្តោងចំនួន ១២០ ០០០ និងលំនៅដ្ឋានចល័តដែលយើងផ្តល់អោយដល់ជនរងគ្រោះដោយខ្យល់ព្យុះហារីកេននិងកាទ្រីណានៅឈូងសមុទ្រ មានបណ្តឹងចំនួន ២០៦ករណី អំពីខ្ពិនចំអ្បែកនិងករណីហ្វ៊រម៉ាល់ដេហាយដ៏ដែល FEMA បានទទួល។ FEMA បានផ្លាស់រថសណ្តោងដែល និងបំពាក់ប្រព័ន្ធបក់ខ្យល់តាមសំណើពីលំនៅដ្ឋាន។ FEMA បានផ្សព្វផ្សាយពត៌មានដល់អ្នករស់នៅតាមរថសណ្តោងទូទាំងប្រទេសអោយបានជ្រួលជ្រាបអំពីភាពងាយនឹងរងគ្រោះដល់សុខភាពបណ្តាលមកពីឥទ្ធិពលហ្វ៊រម៉ាល់ដេហាយដ៏ ហើយយើងក៏បានបង្ហាញពីសកម្មភាពផ្សេងៗដែលអ្នករស់នៅតាមរថសណ្តោងគួរអនុវត្តន៍ដើម្បីកាត់បន្ថយផលប៉ះពាល់ពីហ្វ៊រម៉ាល់ដេហាយដ៏។

## ៧. តើ FEMA មានពត៌មានបង្ហាញថារថសណ្តោងប៉ុន្មានអាចប៉ះពាល់?

យើងក៏រកឃើញមានហ្វ៊រម៉ាល់ដេហាយដ៏នៅតាមរថសណ្តោងថ្មីដែលមិនមានបំពាក់ប្រព័ន្ធបក់ខ្យល់។ ហ្វ៊រម៉ាល់ដេហាយដ៏អាចកាត់បន្ថយបានតាមរយៈការបឺតខ្យល់ ដោយបើកកង្ហារបឺតខ្យល់ និងចំហរកទ្វារនិងបង្អួចក្នុងពេលជាមួយគ្នា ។ កត្តាផ្សេងទៀតដែលប៉ះពាល់ដល់កំរិតហ្វ៊រម៉ាល់ដេហាយដ៏ក្នុងលំនៅដ្ឋានរួមមាន ប្រភេទនិងអាយុកាលសំភារៈផ្សេងៗ អាកាសធាតុ និងសំណើម។ កត្តាសំខាន់ផ្សេងទៀតគឺ បុគ្គលខ្លះឆាប់មានអារម្មណ៍ដឹងថាខ្លួនប៉ះពាល់ដោយហ្វ៊រម៉ាល់ដេហាយដ៏ ជាងបុគ្គលផ្សេងទៀត។

## ៨. តើ FEMA បានប្តូររថសណ្តោងណាខ្លះជាការឆ្លើយតបទៅនឹងពាក្យបណ្តឹងអំពីហ្វ័រម៉ាល់ដេអ៊ីត?

FEMA បន្តប្តូររថសណ្តោងទាំងឡាយណាដែលម្ចាស់ស្នើសុំរថសណ្តោងថ្មី។ មកដល់ត្រឹមថ្ងៃទី ១៥ មិថុនា ២០០៧ FEMA បានប្តូររថសណ្តោងចំនួន ៥៧។ គ្រួសារខ្លះត្អូញត្អែរអំពីភាពកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធបឺតខ្យល់ គ្រួសារខ្លះសំរេចមិនទទួលយកដំណោះស្រាយរបស់ FEMA ធ្វើការផ្លាស់ប្តូររថសណ្តោង រីឯគ្រួសារខ្លះទៀតមានដំណោះស្រាយរបស់ខ្លួនដោយប្តូរទៅរស់នៅក្នុងគេហដ្ឋានអចិន្ត្រៃ ។

## ៩. តើ FEMA បានធ្វើអ្វីខ្លះជាការឆ្លើយតបទៅនឹងបណ្តឹងអំពីការសាយភាយរបស់ហ្វ័រម៉ាល់ដេអ៊ីតនៅក្នុងតំបន់អ្នករស់នៅតាមរថសណ្តោង?

អាទិភាពមួយក្នុងចំណោមអាទិភាពចំបងបង្អស់ដែល FMA កំណត់យកគឺបញ្ហាសុខភាព សុវត្ថិភាព និងសន្តិសុខរបស់ប្រជាជនដែលរស់នៅតាមរថសណ្តោងជាបណ្តោះអាសន្នក្រោយពីរងគ្រោះដ៏អណោចអាធ័មពីគ្រោះមហន្តរាយ។ បន្ទាប់ពីបានដឹងអំពីហ្វ័រម៉ាល់ដេអ៊ីត FEMA បានចាប់ផ្តើមដោយការផ្សព្វផ្សាយដំណឹងដល់អ្នករស់នៅតំបន់នោះអំពីរបៀបបក់ខ្យល់ចេញពីរថសណ្តោង យើងបានសម្រួលប្តូររថសណ្តោង បានផ្តល់នូវជំរើសលំនៅដ្ឋានផ្សេងៗតាមការស្នើសុំនិងតាមលទ្ធភាពរបស់យើង និងបានត្រួតពិនិត្យខ្យល់និងផែនការសំអាតខ្យល់។

ទីភ្នាក់ងាររបសយើងបានពិសោធន៍អំពីកំរិតហ្វ័រម៉ាល់ដេអ៊ីត បានបញ្ជូនបុគ្គលិកផ្នែកលំនៅដ្ឋានចុះទៅសាកសួរអ្នករស់នៅតាមរថសណ្តោងដែលមានបញ្ហាដើម្បីពិភាក្សាអំពីប្រព័ន្ធបក់ខ្យល់ក្នុងរថសណ្តោងរបស់គាត់។ ប្រសិនបើរថសណ្តោង មានក្លិនហ្វ័រម៉ាល់ដេអ៊ីត រឺម្ចាស់ម្ចាស់រថសណ្តោងមានបញ្ហាផ្នែកសុខភាព នោះយើងផ្តល់ដំណោះស្រាយដោយធ្វើការផ្លាស់ប្តូររថសណ្តោងថ្មីជូន ។

## ១០. តើមានជំហានណាខ្លះដែល FEMA បានអនុវត្តន៍ជាការឆ្លើយតបទៅនឹងបញ្ហាដែលលើកឡើងដោយអ្នកជំនាញវេជ្ជសាស្ត្រ?

FEMA បាននឹងកំពុងធ្វើការជាមួយក្រុមអ្នកជំនាញវិទ្យាសាស្ត្រដើម្បីពិនិត្យអំពីក្តីបារម្ភណ៍ផ្សេងៗទាក់ទងនឹងឥទ្ធិពលហ្វ័រម៉ាល់ដេអ៊ីតទៅលើអ្នករស់នៅតាមរថសណ្តោងនៅតាមតំបន់ឈូងសមុទ្រ ដោយផ្អែកលើបញ្ហាថ្មីៗដែលទាញចំណាប់អារម្មណ៍យើង និងសំនួរផ្សេងៗអំពីការប៉ះពាល់ដល់សុខភាពនិងសារធាតុហ្វ័រម៉ាល់ដេអ៊ីត។ ក្នុងដំណើរការវាយតំលៃជាថ្មីនេះ FEMA បានរៀបចំក្រុមដែលមានសមាសភាពពី ការិយាល័យកិច្ចការសុខាភិបាល របស់ក្រសួងសន្តិសុខមាតិភូមិ (DHS OHA) និងទីភ្នាក់ងារចំរុះរបស់មជ្ឈមណ្ឌលគ្រប់គ្រងនិងបង្ការរោគ (CDC)។ ការវាយតំលៃទាំងនេះកំណត់មុខសញ្ញាលើហ្វ័រម៉ាល់ដេអ៊ីត ប៉ុន្តែយើងក៏នឹងធ្វើការវិភាគលំអិតលើរោគសញ្ញាដែលបណ្តាលមកពីព្រភពផ្សេង ។ ទីភ្នាក់ងារទាំងនេះនឹងធ្វើការជាមួយគ្នាដើម្បីរកអោយឃើញពី ទំនាក់ទំនងរវាងគុណភាពខ្យល់ក្នុងរថសណ្តោង និងសុខភាពរបស់អ្នកតាំងទីលំនៅតាមរថសណ្តោងទាំងនោះ។

## ១១. តើ FMA បានផ្លាស់ប្តូរគោលនយោបាយណាខ្លះទាក់ទងនឹងកំរិតហ្វ័រម៉ាល់ដេអ៊ីតដែលអាចទទួលយកបាននៅក្នុងលំនៅដ្ឋានរថសណ្តោងចាប់ពីពេលដែលអ្នករស់នៅតាមតំបន់ឈូងសមុទ្របានប្តឹង?

FEMA បានអនុវត្តន៍តាមមាត្រដ្ឋានផ្សេងៗដែលកំណត់ដោយ ក្រសួងអភិវឌ្ឍន៍លំនៅដ្ឋាននិងរៀបចំក្រុង (HUD)។ មាត្រដ្ឋានទាំងនោះផ្តល់លទ្ធភាពអោយយើងគ្រប់គ្រងនិងត្រួតពិនិត្យកំរិតសាយភាយរបស់ហ្វ័រម៉ាល់ដេអ៊ីត នៅក្នុងផលិតផលឈើដែលទីភ្នាក់ងាររបស់យើងត្រូវទិញសំរាប់កសាងលំនៅដ្ឋានចល័តដល់ ទាំងអ្នករស់នៅតាមរថសណ្តោង

និងអ្នករស់នៅជាលក្ខណៈចំណត។ លំនៅដ្ឋានចំណតមានទ្រង់ទ្រាយធំជាង លំនៅដ្ឋានរថសណ្តោង ប៉ុន្តែវាមានទ្រង់ទ្រាយតូចជាងសហគ្រាសផលិតសំភារៈគេហដ្ឋាន។

មាត្រដ្ឋានរបស់ HUD អនុវត្តន៍ដោយកំរិតព្រំដែនសាយភាយរបស់ហ្វ៊ម៉ាល់ដេហាយដ៍ និងគ្រប់គ្រងលិខិតបញ្ជាក់ធ្វើអាជីវកម្មផលិតផលឈើ និងរាល់សំភារៈកំទេចឈើ(កុងត្រាកេ) ក៏ដូចជាលិខិតបញ្ជាក់ស្តីពីភាពសាយភាយដែលទទួលស្គាល់ដោយមន្ទីរពិសោធន៍ជាតិ និងការគ្រប់គ្រងគុណភាពដើមឈើនិមួយៗដែលត្រូវប្រើដើម្បីផលិតសំភារៈកំទេចឈើ។ មាត្រដ្ឋានទាំងនេះបានកំណត់ឡើងដោយ HUD សំរាប់គ្រប់គ្រងសហគ្រាសផលិតសំភារៈគេហដ្ឋាន ហើយឥឡូវនេះ FEMA បានចំលងយកមកអនុវត្តន៍នៅតាមមូលដ្ឋានរថសណ្តោង។

មាត្រដ្ឋានរបស់ HUD ក៏តំរូវអោយសហគ្រាសផលិតសំភារៈគេហដ្ឋានធ្វើរបាយការណ៍សុខភាពស្តីពីការសាយភាយរបស់ហ្វ៊ម៉ាល់ដេហាយដ៍ ដែលកំណត់ដោយមាត្រដ្ឋានលេខ ៣២៨០.៣០៩ ។ ផ្អែកលើលទ្ធផលនៃការ វិភាគពីផលប៉ះពាល់នៃសារធាតុហ្វ៊ម៉ាល់ដេហាយដ៍ដែលសិក្សាដោយទីភ្នាក់ងារទទួលខុសត្រូវជំនាញ យើងនឹងបង្កើតនូវមាត្រដ្ឋានមួយដែលសំរួលតាមមាត្រដ្ឋានខាងលើ។

FEMA នឹងធ្វើការសំរេចចិត្តលើបញ្ហាគោលការណ៍ វីលើជំនួយបន្ថែមសំរាប់អ្នករស់នៅតាមរថសណ្តោង ដោយផ្អែកលើលទ្ធផលនៃកាសិក្សាវិភាគរបស់អ្នកជំនាញផ្នែកសុវត្ថិភាព និងសុខភាពរបស់យើង។

###